**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

ថ្ងៃ សុក្រ ១៤ រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព. ស. ២៥៦៦

លេខ ៣២៦/២២ ក. ស. ក.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០២២

# សេចក្តីជូនដំណឹងលើកទី២

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃជាសាធារណៈលើការផ្គត់ផ្គង់ចង្កៀងសូឡាម៉ាក SL-៧០ និងចង្កៀងសូឡាម៉ាក SL-C៣១០ សម្រាប់បម្រើការងារជួសជុលនិងថែទាំពោងសញ្ញា/GPS សម្រាប់ឆ្នាំ២០២២

កំពង់ផែស្វយ័តភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា កំពង់ផែស្វយ័តភ្នំពេញ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈលើការផ្គត់ផ្គង់ចង្កៀងសូឡាម៉ាក SL-៧០ និងចង្កៀងសូឡាម៉ាក SL-C៣១០ សម្រាប់បម្រើការងារជួសជុលនិងថែទាំពោងសញ្ញា/GPS សម្រាប់ឆ្នាំ២០២២។

កំពង់ផែស្វយ័តភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មកំពង់ផែស្វយ័តភ្នំពេញ ដែលមានអាសយដ្ឋានអគារលេខ ៦៤៩ តិរៈវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ **ចាប់ពីថ្ងៃទី**២៩**ខែ**សីហា **ឆ្នាំ២០២២ តទៅរៀងរាល់ម៉ោងធ្វើការ** (ទូរស័ព្ទទាក់ទងលេខ ០១០ ៤៤៤ ៦៤១)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ **នៅម៉ោង**១៤:៣០នាទី**ថ្ងៃទី**១២**ខែ**កញ្ញា**ឆ្នាំ២០២២។**

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ **វេលាម៉ោង** ១៤:៣០នាទី**ថ្ងៃ**១២**ខែ**កញ្ញា**ឆ្នាំ២០២២។**

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានអគ្គនាយក និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ហ៊ី-បាវី**

**ចម្លងជូន ៖**

- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ

ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ តិរៈវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៤២៧ ៨០២ Email: ppapmpwt@online.com.kh